CAMBODIA
TOURISM
BOARD

# សេចក្តីជូនដំណឹង

ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (CTB) សូមជម្រាបជូនសាធារណជនអំពីព័ត៌មានពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការរវាង CTB និង ក្រុមហ៊ុនTrip.Com តទៅ៖

១. កិច្ចព្រមព្រៀងសហប្រតិបត្តិការរវាង CTB និង ក្រុមហ៊ុនTrip.com គឺផ្តោតសកម្មភាពផ្សព្វផ្សាយទេសចរណ៍ ដែលមានរយៈពេលពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៥ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦។ កិច្ចសហប្រតិបត្តិការនេះ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់ CTB ក្នុងការរួមចំណែកអនុវត្ត "ឆ្នាំទេសចរណ៍កម្ពុជា-ចិន២០២៥" ដែលត្រូវបានកំណត់រួមគ្នាដោយថ្នាក់ដឹកនាំ នៃប្រទេសទាំងពីរ កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៥។

២. CTB និង ក្រុមហ៊ុនTrip.com បានព្រមព្រៀងគ្នាផ្អាកសកម្មភាពផ្សព្វផ្សាយដែលបានគ្រោងទុក នៅតាមបណ្តាញផ្សព្វផ្សាយរបស់ក្រុមហ៊ុន Trip.com Group រហូតដល់កាលៈទេសៈអំណោយផលឡើងវិញ។

៣. CTB សូមបញ្ជាក់ថា តាមរយៈកិច្ចព្រមព្រៀងនេះ ឬតាមរយៈកិច្ចសហប្រតិបត្តិការផ្សេងទៀត CTB មិនដែលបានស្នើសុំទទួល ប្រើប្រាស់ រក្សាទុក វិភាគ ឬចែកចាយនូវ ទិន្នន័យផ្ទាល់ខ្លួនរបស់ភ្ញៀវទេសចរឡើយ។

៤. CTB បន្តការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការផ្សព្វផ្សាយកម្ពុជាជាគោលដៅទេសចរណ៍ ប្រកបដោយសុវត្ថិភាព សន្តិសុខ និងការស្វាគមន៍ សម្រាប់ភ្ញៀវទេសចរទាំងអស់ដែលមកកាន់ព្រះរាជាណាចក្រកម្ពុជា និងប្រកាន់ខ្ជាប់នូវការអនុវត្តការផ្សព្វផ្សាយទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ និងតម្លាភាព។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០២៥

CAMBODIA TOURISM BOARD